

# ព័ត៌មានកម្មវិធី SPCR
# ការប្រែប្រួលអាកាសធាតុ


អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | នាយកដ្ឋានប្រែប្រួលអាកាសធាតុ

កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) | ខែកញ្ញា ឆ្នាំ២០១៥ លេខ ៣


## ក្រុមការងារការបន្សាំនឹងការប្រែប្រួលអាកាសធាតុចុះពិនិត្យមើលភាពធន់នឹងអាកាសធាតុលើវិស័យពាក់ព័ន្ធ




*កិច្ចប្រជុំនៅសាលាខេត្តចែករំលែកបទពិសោធន៍ និងពិភាក្សាអំពីតំបន់គោលដៅសម្រាប់ចុះសិក្សាពីការបន្សុាំនឹងការប្រែប្រួលអាកាសធាតុនៅខេត្តព្រៃវែង*

ពីថ្ងៃទី២៤ ដល់ទី២៨ ខែសីហា ឆ្នាំ២០១៥ ក្រុមការងារគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) នៅក្រោមនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថានដែលបានដឹកនាំដោយឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត **សាបូ អូហ្សាណា** រដ្ឋលេខាធិការក្រសួងបរិស្ថាននិងជាប្រធានសម្របសម្រួលកម្មវិធី (MCRDP) បានចុះបេសកកម្មទៅកាន់ខេត្តព្រៃវែង ដើម្បីអង្កេតមើលការអនុវត្តការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ នៅតាមសហគមន៍ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ធនធានទឹក ការអភិវឌ្ឍផ្លូវថ្នល់ និងទីក្រុង។ ក្នុងឱកាសនោះ ឯកឧត្តម **ឡុង ថាត** អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង ក៏បានសហការយ៉ាងជិតស្និទ្ធ និងសម្របសម្រួលចុះដល់ទីតាំងជាក់ស្តែង ដោយបានអញ្ជើញមន្ត្រីរាជការពាក់ព័ន្ធចូលរួមដើម្បីកំណត់បញ្ហាប្រែប្រួលអាកាសធាតុ និងដំណោះស្រាយការបន្សុាំដែលមាននៅក្នុងភូមិសាស្ត្រស្រុកបាភ្នំ កំពង់ត្របែក ពាមរក៍ ស្វាយអន្ទរ ពារាំង កំចាយមារ ក្រុងព្រៃវែង និងព្រះស្តេច។

ក្រុមការងារការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ[១] រួមទាំងជនបង្គោលប្រែប្រួលអាកាសធាតុអញ្ជើញពីក្រសួង ស្ថាប័នពាក់ព័ន្ធ បានចូលរួមអនុវត្តលើផ្នែកសំខាន់ៗនៃគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (MCRDP) ដោយមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀត។ ក្រុមការងារការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ចូលរួមការវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សុាំជាមួយក្រុមការងារបច្ចេកទេសរបស់គម្រោង និងគាំទ្រដំណើរការនៃការបង្កើតអនុសាសន៍គោលនយោបាយដើម្បីបង្កើនភាពធន់នឹងអាកាសធាតុសម្រាប់វិស័យនីមួយៗ។ គោលបំណងរបស់ក្រុមការងារការបន្សុាំនឹងការប្រែប្រួលអាកាសធាតុចុះពិភាក្សាទៅខេត្តព្រៃវែង គឺដើម្បីកំណត់ការអនុវត្តនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលថ្លៃថ្លាដែលមានស្រាប់ក្នុងវិស័យកសិកម្ម ការគ្រប់គ្រង

[១] *ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងផែនការ, ក្រសួងកិច្ចការនារី, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*

ធនធានទឹក និងការអភិវឌ្ឍផ្លូវថ្នល់ និងទីក្រុងដែលត្រូវបានបង្ហាញឲ្យឃើញពីភាពធន់នឹងអាកាសធាតុ និងមួយចំនួនទៀតបង្ហាញឱ្យឃើញពីភាពធន់នឹងអាកាសធាតុតិចតួច ដោយពិនិត្យមើលទាំងការអនុវត្តតាមបែបប្រពៃណី និងទំនើបកម្ម។

ខេត្តព្រៃវែង មានចំងាយប្រមាណ៩៥គីឡូម៉ែត្រពីរាជធានីភ្នំពេញនៃភាគខាងកើតប្រទេសកម្ពុជា ដែលត្រូវបានចាត់ទុកជាខេត្តងាយរងគ្រោះជាងគេនៅក្នុងផែនការសកម្មភាពជាតិការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ខេត្តព្រៃវែង ត្រូវបានទន្លេមេគង្គ និងទន្លេចំនួន០៣ទៀតហូរកាត់ចំនួន១២ស្រុក និងក្រុងព្រៃវែង។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើធនធានទឹក គឺជាបញ្ហាសំខាន់មួយដែលខេត្តនេះប្រឈមនឹងផលិតភាពសេដ្ឋកិច្ចកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ការអភិវឌ្ឍផ្លូវថ្នល់ និងទីក្រុង។ ធនធានទឹករបស់ខេត្តនេះ គឺអាស្រ័យលើរបបទឹកជំនន់ទន្លេមេគង្គ និងទទួលរងនូវរដូវទឹកជំនន់ និងរដូវប្រាំងហួសប្រមាណព្រោះរបបនេះប្រែក្លាយទៅជាមិនបានទៀងទាត់ដោយសារការប្រែប្រួលអាកាសធាតុ និងភាពប្រឈម។ ករណីសិក្សានីមួយៗ នឹងត្រូវបានចងក្រងយ៉ាងលម្អិតនាខែវិច្ឆិកា ឆ្នាំ២០១៥ ហើយខាងក្រោមនេះជាព័ត៌មានស្វែងយល់សង្ខេបពីការអនុវត្តមួយចំនួនដើម្បីចងក្រងទុកជាឯកសារ។

## ការអនុវត្តភាពធន់នឹងអាកាសធាតុតាមវិស័យ

**ប្រព័ន្ធស្រោចស្រពដំណក់ទឹកសម្រាប់ការធ្វើកសិកម្ម៖** លោក ញ៉ែម ឆត់ ជាកសិករក្នុងភូមិក្រូច ឃុំកន្សោមអក ស្រុកកំពង់ត្របែក គាត់បានចាប់ផ្តើមដាក់បញ្ចូលប្រព័ន្ធស្រោចស្រពដំណក់ទឹក និងគ្របចំបើង (គ្របលើដំណាំដើម្បីបន្ថែមគុណភាពដី) ដែលអាចឱ្យគាត់ធ្វើការដាំដុះបាន០៣ដងក្នុងមួយឆ្នាំ បើទោះបីខេត្តព្រៃវែងប្រឈមនឹងការខ្វះទឹកក៏ដោយ។ កសិករក៏បានជីកប្រឡាយជុំវិញចំការដើម្បីរក្សាទឹកទុកសម្រាប់ប្រើប្រាស់នាពេលក្រោយៗទៀត។ ទន្ទឹមនឹងនេះ គាត់ក៏បានជីកអណ្តូងទឹកក្រោមដី ដែលគាត់ត្រូវបូមទឹកយកមកប្រើប្រាស់ក្នុងកំឡុងពេលជួបគ្រោះរាំងស្ងួតខ្លាំង។



**ការដាំដំណាំឆ្លាស់នៅភូមិជាខ្លាង ស្រុកស្វាយអន្ទរ ៖** អ្នកស្រី ផេង ធី ជាកសិករដែលរកបង្កើនប្រាក់ចំណូលដោយការដាំដំណាំឆ្លាស់។ ស្ថិតនៅលើផ្ទៃដី០២ហិកតា គាត់ប្រើដី០១ហិកតា សម្រាប់ដាំអំពៅ និងស្រូវ។ ចំណែក០១ហិកតាទៀត ត្រូវបានប្រើប្រាស់សម្រាប់ការដាំបន្លែច្រើនមុខ។ ពីខែឧសភា ដល់ខែតុលា គាត់ធ្វើស្រែដែលអាចរកប្រាក់ចំណូលបានពី៥ទៅ៦លានរៀលក្នុងមួយរដូវ (ប្រហែល ១២៥០ ទៅ១៥០០ ដុល្លារសហរដ្ឋអាមេរិក)។ គាត់ប្រមូលផលដំណាំអំពៅចាប់ពីខែវិច្ឆិកា ដោយក្នុង០១ហិកតាដំណាំអំពៅ គាត់អាចរកចំណូលបានប្រហែល៣០លានរៀលក្នុងមួយឆ្នាំ។ គាត់ក៏បង្កើនប្រាក់ចំណូលនេះ ដោយដាំបន្លែពេញមួយឆ្នាំទៀតផង។ ការអនុវត្តដាំដំណាំឆ្លាស់នេះ អាចឱ្យគាត់ជ្រើសរើសប្រភេទដំណាំដែលអាស្រ័យលើពេលវេលាដែលមានទឹក ឬគ្មានទឹក។ ជាមួយជម្រើសនៃការដាំដុះពេញមួយឆ្នាំ អ្នកស្រី ផេង ធី អាចកាត់បន្ថយភាពងាយរងគ្រោះលើការដាំដុះរបស់គាត់នៅរដូវទឹកជំនន់ ឬរដូវប្រាំង។ ជាលទ្ធផល ជីវភាពរស់នៅរបស់គាត់ គឺកាន់តែមានភាពធន់នឹងអាកាសធាតុ។ នេះក៏ដោយសារតែមានទីផ្សារសម្រាប់ប្រមូលទិញផលិតផលដើមអំពៅដែរ។



**ការចូលរួមរបស់ស្ត្រីក្នុងការរៀបចំប្រព័ន្ធស្រោចស្រព និងការថែទាំ៖** ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមធ្វើឱ្យជីវភាពរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ។ ស្ត្រីនៅភូមិទ្រាក្នុងខេត្តព្រៃវែង ដែលពួកគាត់ភាគច្រើនជាអ្នកធ្វើការនៅរោងចក្រកាត់ដេរ បានចូលរួមយ៉ាងសកម្មក្នុងការថែទាំប្រឡាយនៅក្នុងសហគមន៍។ រៀងរាល់ចុងសប្តាហ៍ ស្ត្រីបាននាំគ្នាដើរច្រូតស្មៅដែលមាននៅជិតផ្ទះរបស់គាត់ ដើម្បីយកទៅដាំនៅតាមដើងទេរប្រឡាយដើម្បីឱ្យរឹងមាំពេលមានភ្លៀងធ្លាក់ខ្លាំង។

**តំបន់សុវត្ថិភាពសហគមន៍ និងការចិញ្ចឹមសត្វ៖** នៅភូមិកំពង់ស្លែង ស្រុកបាភ្នំ-ភូមិនេះមានអ្នកស្រុកចំនួន ២៤៥គ្រួសារត្រូវបានទឹកជន់លិចជារៀងរាល់ឆ្នាំ។ អ្នកភូមិត្រូវទៅតាំងទីលំនៅថ្មី នៅទីកន្លែងដែលមានដីទួលសុវត្ថិភាពដែលអាចចិញ្ចឹមសត្វ និងប្រជាពលរដ្ឋស្នាក់នៅទីនោះកំឡុងពេលទឹកជំនន់ឡើងខ្លាំង។



## ភាពប្រឈមសម្រាប់ភាពធន់នឹងអាកាសធាតុ

**ការប្រើប្រាស់ទឹកក្រោមដីសម្រាប់ការធ្វើកសិកម្ម៖** កសិករនៅភូមិក្រាំង ក្នុងឃុំទ្រាយ ស្រុកបាភ្នំ បានប្រើប្រាស់ទឹកក្រោមដីដើម្បីធ្វើស្រែ។ កាលពី០៥ឆ្នាំមុន ដោយសារកាន់តែមានបញ្ហាពិបាកខ្លាំងឡើងពីការខ្វះខាតទឹក កសិករបានចាប់ផ្តើមជីកអណ្តូងទឹក និងបូមទឹកអណ្តូងដាក់ស្រែនៅរដូវប្រាំង។ ការអនុវត្តបែបនេះជាដំណោះស្រាយសម្រាប់រយៈពេលខ្លីប៉ុណ្ណោះសម្រាប់ការខ្វះខាតទឹក ហើយការបូមទឹកដែលជាតម្រូវការរបស់អ្នកភូមិច្រើននាក់ក្នុងពេលតែមួយដែលធ្វើឱ្យកម្រិតទឹកដែលមានកាន់តែទាបទៅៗ ប្រហែលអាចនឹងធ្វើឲ្យគ្មានទឹកទៀតក្នុងរយៈពេលយូរ។ ការបូមទឹកដែលមិនមានការគ្រប់គ្រងត្រឹមត្រូវ អាចប្រឈមនឹងតំបន់រក្សាទឹកទុកក្រោមដីជារៀងរហូត ដែលនាំឱ្យកាត់បន្ថយបរិមាណទឹកឱ្យមានដូចដើមវិញ និងជាលទ្ធផលអាចបណ្តាលឱ្យខ្វះខាតទឹកខ្លាំងនៅពេលអនាគត។

## ផ្សព្វផ្សាយជ្រើសរើសសង្គមស៊ីវិលចូលរួមអនុវត្តសកម្មភាព<br>ដើម្បីភាពធន់នឹងអាកាសធាតុ

ការកសាងសមត្ថភាពដល់អង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយការបន្សាំនឹងការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពចំបងរបស់កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)។ គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ SPCR បានចាប់ផ្តើមផ្សព្វផ្សាយជ្រើសរើសអង្គការសង្គមស៊ីវិលនានាប្រកួតប្រជែងដែលមានការចាប់អារម្មណ៍ដាក់សំណើគម្រោងដែលមានយុទ្ធសាស្ត្រផ្តួចផ្តើមច្នៃប្រឌិត ដើម្បីទទួលបានកញ្ចប់ថវិកាតូចៗយកទៅអនុវត្តសកម្មភាពរបស់ខ្លួន។ កាលពីខែសីហាអង្គការផ្លែន Plan International Cambodia ) បានផ្សព្វផ្សាយជ្រើសរើសយ៉ាងទូលំទូលាយដល់អង្គការសង្គមស៊ីវិលនៅកម្ពុជាដែលចាប់អារម្មណ៍ដើម្បីដាក់សំណើគម្រោង។ មានសំណើដែលចាប់អារម្មណ៍គម្រោងសរុបចំនួន១១៦ ត្រូវបានទទួលកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ តាមកាលបរិច្ឆេទដែលបានកំណត់ ហើយសំណើគម្រោងទាំងនោះ ផ្តោតលើវិស័យផ្សេងៗគ្នាដូចជាបទអន្តរាគមន៍ ក្រុមគោលដៅ និងតំបន់ភូមិសាស្ត្រនៅកម្ពុជា។

- អង្គការសង្គមស៊ីវិល បានបង្ហាញពីការចាប់អារម្មណ៍ធ្វើការក្នុងវិស័យផ្សេងៗជាមួយសកម្មភាពដែលស្មើឡើងភាគច្រើនលើកសិកម្ម (៧០% បន្ទាប់មកការគ្រប់គ្រងធនធានទឹក (៣៩%) និងជីវភាពរស់នៅ (៣៤%) ដោយផ្តោតលើការអភិវឌ្ឍទីក្រុង សុខភាព និងអនាម័យ និងផ្លូវថ្នល់។២៤%នៃសំណើគម្រោង មានសមាសភាគការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ២៣% មានសមាសភាគក្រុមឱ្យខ្ចី និងសន្សំប្រាក់ ឬធនាគារគ្រាប់ពូជ ២២% សមាសភាគប្រព័ន្ធផ្សព្វផ្សាយ និងស្វែងរកមតិគាំទ្រ និង១៦% ផ្តោតលើយុវជន។
- សំណើចំណាប់អារម្មណ៍ ផ្តោតលើក្រុមគោលដៅជាស្ត្រី កុមារ ប្រជាពលរដ្ឋដែលងាយរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ក្រុមជនជាតិភាគតិច និងកសិករ។
- មានសំណើចំណាប់អារម្មណ៍តិចតួចដែលផ្តោតលើប្រជាពលរដ្ឋក្រីក្រនៅទីក្រុង និងជួយគាំទ្រដល់ចាស់ជរា។
- តំបន់ភូមិសាស្ត្រដែលភាគច្រើនលើកឡើងមានតំបន់ជុំវិញបឹងទន្លេសាបនិងភាគខាងកើតប្រទេស។ ចំណែកតំបន់ឆ្នេរ និងខាងលិចមិនសូវបានលើកឡើងក្នុងសំណើចំណាប់អារម្មណ៍ទេ។

ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និងទាញយកចំណាប់អារម្មណ៍ឱ្យកាន់តែច្រើនឡើង នៅក្នុងវិស័យពាក់ព័ន្ធ និងប្រជាពលរដ្ឋ គម្រោងបានពន្យាកាលបរិច្ឆេទទទួលយកសំណើចំណាប់អារម្មណ៍រហូតដល់ខែកញ្ញា ឆ្នាំ២០១៥ដោយទទួលបាន១៣៥សំណើចំណាប់អារម្មណ៍។

ក្នុងចំណោមសំណើចំណាប់អារម្មណ៍របស់អង្គការសង្គមស៊ីវិល សំណើចំនួន៣៥ ត្រូវបានជ្រើសរើសនឹងត្រូវអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល២លើក។ ការជ្រើសរើសនឹងធ្វើឡើងអាស្រ័យលើលក្ខណៈវិនិច្ឆ័យដែលផ្តល់អាទិភាពដល់គម្រោងដោយផ្តោតលើយេនឌ័រ ការចូលរួម ការច្នៃប្រឌិត និរន្តរភាព និងការទទួលបានផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលងាយរងគ្រោះ(រួមមានស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនជាតិដើមភាគតិច)។ បន្ទាប់ពីការបណ្តុះបណ្តាល អង្គការសង្គមស៊ីវិល ដែលត្រូវបានជ្រើសរើស នឹងរៀបចំសំណើពេញលេញដោយបញ្ជូនមកអង្គការ Plan International Cambodia ដើម្បីជ្រើសរើសជាមួយអ្នកពាក់ព័ន្ធ។ កញ្ចប់ថវិកាតូចៗ នឹងត្រូវផ្តល់ជូនជាបន្តបន្ទាប់ដល់សំណើចំនួនចាប់ពី២០ដល់២៥។ អង្គការសង្គមស៊ីវិលដែលដាក់សំណើគម្រោង នឹងអនុវត្តគម្រោងការបន្សាំក្នុងសហគមន៍។ អង្គការសង្គមស៊ីវិលនឹងទាញយកផលប្រយោជន៍ពីការចូលរួមវគ្គបណ្តុះបណ្តាល និងការណែនាំនានា ដោយមានគោលបំណងដើម្បីជម្រុញអង្គការសង្គមស៊ីវិលដាក់បញ្ចូលទស្សនវិស័យការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីទូទៅរបស់ខ្លួន។ គម្រោងតូចៗទាំងនោះនឹងត្រូវបានអនុវត្តក្នុងក្របខណ្ឌរយៈពេល១៨ខែ ដោយចាប់ផ្តើមដើមឆ្នាំ២០១៦។

កម្មវិធីនេះ ជាការបន្ថែមលើកិច្ចខិតខំប្រឹងប្រែងកាន់តែទូលំទូលាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ដើម្បីកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងឈានទៅចូលរួមអនុវត្តសម្រេចបាននូវគោលដៅរបស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី០៣ (២០១៣-២០១៨) ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) និងគោលនយោបាយដទៃទៀត។ យន្តការគាំទ្រអង្គការសង្គមស៊ីវិល ត្រូវបានរៀបចំឡើងដើម្បីធានាថាអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិសហការជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់ត្រៀមលក្ខណៈរួចរាល់ដើម្បីចូលរួម អនុវត្តយុទ្ធសាស្ត្រជាតិការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងដំណើរការឆ្ពោះទៅមុខ។

*សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង លោកអ្នកអាចទាក់ទងលោក យន់ ស៊ីណា អ្នកជំនាញជាតិកសាងសមត្ថភាពនៃអង្គការផ្លែន តាមរយៈ sina.yun@plan-international.org*

## កសិករចែករំលែកទស្សនៈស្តីពីការប្រែប្រួលអាកាសធាតុ

ប្រជាពលរដ្ឋកម្ពុជាកាន់តែដឹងឮពីការប្រែប្រួលអាកាសធាតុ និងចាប់ផ្តើមកាន់តែយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។ តាមការចុះជាក់ស្តែងទៅខេត្តព្រៃវែងនាពេលថ្មីៗនេះ កសិករភាគច្រើនយល់ថាការប្រែប្រួលអាកាសធាតុជាការកើនឡើងសីតុណ្ហភាពរយៈពេលយូរដែលប៉ះពាល់ដល់លក្ខខណ្ឌធាតុអាកាសក្នុងប្រទេស។ តាមការសួរនាំភាគច្រើនពីប្រជាជន ទទួលរងផលប៉ះពាល់អវិជ្ជមានពីការប្រែប្រួលអាកាសធាតុមកលើសុខភាព និងការធ្វើស្រែចំការកាន់តែពិបាក។ ចំណែកអ្នកផ្សេងទៀតក៏ទទួលរងផលប៉ះពាល់ដែលធ្វើឲ្យទទួលបានទិន្នផលដំណាំតិច កាន់តែរាំងស្ងួត សីតុណ្ហភាពកើនឡើង និងទឹកជំនន់។ កសិករបានបង្ហាញពីការខ្វះខាតថវិកា ធនធានមនុស្ស និងសម្ភារៈដើម្បីដោះស្រាយបញ្ហាបណ្តាលមកពីការប្រែប្រួលអាកាសធាតុផងដែរ។




ទោះបីជាយ៉ាងណា នៅតាមគ្រួសារមួយចំនួនក្នុងសហគមន៍បានចាត់ចែងដោះស្រាយដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដូចខាងក្រោម៖

កសិករនៅឃុំជ្រៃក្នុងខេត្តព្រៃវែង លោក សុខ សារឿន បានពន្យល់ពីរបៀបដែលគាត់ធ្វើស្រែ និងដាំដំណាំផ្សេងៗដើម្បីចិញ្ចឹមគ្រួសារ។ កាលពីមុន គាត់អាចដាំដំណាំតែនៅរដូវវស្សា ដោយសារគ្មានទឹកនៅរដូវប្រាំងកាលពីមិនទាន់មានប្រឡាយ ដែលត្រូវបានស្តារឡើងវិញនៅតាមផ្លូវមុខផ្ទះរបស់គាត់។ គាត់ដឹងពីការប្រែប្រួលអាកាសធាតុ តាំងពីយូរណាស់មកហើយតាមរយៈការអង្កេតរបស់គាត់។ គាត់បានកត់សម្គាល់ថា ប្រជាពលរដ្ឋនៅភូមិរបស់គាត់ធ្លាប់មានទឹកប្រើប្រាស់គ្រប់គ្រាន់ដើម្បីដាំដំណាំទាន់ពេលវេលា។ ប៉ុន្តែឥឡូវដំណាំទាំងនោះពិបាកដាំដុះដោយសារមិនមានភ្លៀងធ្លាក់គ្រប់គ្រាន់។ ម្យ៉ាងវិញទៀត ក៏មិនមានប្រភពទឹកផ្សេងៗទៀតឡើយក្រៅពីទឹកភ្លៀងហើយការបូមទឹកពីប្រឡាយនៅមុខផ្ទះដែលជាដំណោះស្រាយ ក៏មិនគ្រប់គ្រាន់ដែរសម្រាប់ការប្រើប្រាស់ដោយសារមានតម្រូវការខ្ពស់ពីកសិករទាំងអស់។ នៅពេលមានគ្រោះរាំងស្ងួត ក៏មិនមានជម្រើសអ្វីក្រៅពីរង់ចាំទឹកភ្លៀង។ នៅពេលអនុវត្តការបន្សាំដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ កសិកររូបនេះក៏បានព្រួយបារម្ភពីរបៀបនៃការគ្រប់គ្រងទឹកឱ្យកាន់តែល្អដើម្បីបំពេញតម្រូវការរបស់កសិករបានទាំងអស់។





# ៥ ព័ត៌មានកម្មវិធីSPCR

កសិករ គីម ស្រីភាព ពីឃុំធាយ បានអង្កេតឃើញថាធាតុអាកាសកាន់តែប្រែប្រួលក្តៅឡើងៗនៅរដូវប្រាំងធ្វើឱ្យពិបាកចិញ្ចឹមសត្វ ដាំបន្លែ និងធ្វើស្រែ។ ដើម្បីដោះស្រាយបញ្ហានេះ កសិករភាគច្រើនបានចាប់ផ្តើមផ្លាស់ប្តូរពីការស្ទូងស្រូវនៅវាលស្រែដែលមានទឹកដក់មកជាការព្រួសស្រូវលើដីដែលមានសំណើមតិចៗ។ អ្នកជិតខាងរបស់គាត់ គឺអ្នកស្រី ជា ណារី ក៏ធ្លាប់ឮពីការប្រែប្រួលអាកាសធាតុដែរកាលពី៤-៥ឆ្នាំមុន។ គាត់បានកត់សម្គាល់ថា ធាតុអាកាសកាន់តែក្តៅឡើង និងមានខ្យល់កន្ត្រាក់ញឹកញាប់ទៀតផង។ ភ្លៀងមិនទៀងទាត់ក៏ជាមូលហេតុចំបងបណ្តាលឱ្យប៉ះពាល់ដល់ការធ្វើស្រែចំការដែលធ្វើឱ្យកសិករមានក្តីបារម្ភដើម្បីធ្វើសេចក្តីសម្រេចចិត្តពេលណាគួរត្រូវព្រួស ឬស្ទូងនោះ។ ចំណែកកូនរដូវប្រាំងវិញតែងតែចាប់ផ្តើមរវាងពីចុងខែកក្កដា និងដើមខែសីហា។

កសិករដទៃទៀតនៅតំបន់នេះ ក៏បូមទឹកដាក់ស្រែដែរ ដោយសារការពង្រីកប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត។ ដោយមូលហេតុនេះ គណៈកម្មការប្រើប្រាស់ទឹកកសិករ ត្រូវបានបង្កើតឡើង។ គណៈកម្មការនេះជួយសហគមន៍ ឬឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយផ្គត់ផ្គង់ទឹកពីប្រព័ន្ធធារាសាស្ត្រកំឡុងពេលគ្រោះរាំងស្ងួត។ ឧទាហរណ៍៖ គណៈកម្មការប្រើប្រាស់ទឹកកសិករបឹងស្នេហ៍នៅខេត្តព្រៃវែង ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងទឹកសម្រាប់ការធ្វើកសិកម្មដែលបម្រើឱ្យប្រជាកសិករប្រមាណ៣៤ភូមិ ដែលមាន៥៥២៧គ្រួសារ ក្នុងឃុំចំនួន០៦។ ការផ្លាស់ប្តូរក្នុងការគ្រប់គ្រងទឹកសម្រាប់ការប្រើប្រាស់នេះ ធ្វើឱ្យគាត់អាចធ្វើស្រែបាន០៣ដងក្នុងមួយឆ្នាំពីអាងស្តុកទឹកដែលមានចំណុះប្រមាណ៨០លានម៉ែត្រគីប។

ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសងាយរងគ្រោះ ដោយសារពឹងផ្អែកខ្លាំងលើកសិកម្ម និងវិស័យពាក់ព័ន្ធអាកាសធាតុដទៃទៀតហើយសមត្ថភាពការបន្សុំនៅមានកម្រិតទាបនៅឡើយ។ ការផ្លាស់ប្តូរទម្លាប់ដើម្បីបន្សុំនឹងការប្រែប្រួលអាកាសធាតុ កំពុងត្រូវបានផ្លាស់ប្តូរនៅក្នុងសហគមន៍ដោយសារស្រ្តី និងបុរសកាន់តែយល់ដឹងពីផលប៉ះពាល់ដែលកើតចេញពីសកម្មភាពរាល់ថ្ងៃរបស់ពួកគាត់ ពិសេសផលិតកម្មកសិកម្ម។ តាមរយៈការយល់ដឹងនេះ កសិករកម្ពុជាកំពុងកាន់តែចាប់អារម្មណ៍ដើម្បីកសាងចំណេះដឹងពីការអនុវត្តថ្មីៗសម្រាប់ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ។

**សម្រាប់ព័ត៌មានបន្ថែម៖**

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ ប្រធានសម្របសម្រួលកម្មវិធី

លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

អាគារ ៤៨ មហាវិថី សម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧  អ៊ីម៉ែល៖ adbspcrta8179@gmail.com